ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កំណត់ហេតុប្រជុំ

## ស្តីពីករណីព្យួរកិច្ចសន្យាការងារ

ឆ្នាំពីរពាន់ម្ភៃ ខែ មេសា ថ្ងៃទីម្ភៃ វេលាម៉ោងប្រាំបួន និងសាមសិប នាទីព្រឹក មានកិច្ចប្រជុំមួយនៅសាលប្រជុំក្រុមហ៊ុន លៀនហ្វា (ខេមបូឌា) ហ្គាមេន ដែលមានទីតាំងស្ថិតនៅភូមិ ព្រែកសំរោង ក្រុងតាខ្មៅ ខេត្តកណ្តាល ស្តីពីករណីព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ក្រោមអធិបតីភាពលោក QUE WENLOU ជានាយកក្រុមហ៊ុន ដោយមានការចូលរួមពីលោក-លោកស្រី សហជីព និងប្រតិភូបុគ្គលិកប្រចាំក្រុមហ៊ុន (ជូនភ្ជាប់បញ្ជីវត្តមាន)។

ជាកិច្ចចាប់ផ្តើម លោកនាយក QUE WENLOU បានបើកកិច្ចប្រជុំ និងបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លោក-លោកស្រី ជាភាគីតំណាងកម្មករនិយោជិត (ប្រតិភូបុគ្គលិក) ដែលបានចំណាយពេលអញ្ជើញចូលរួមប្រជុំនៅថ្ងៃនេះ។ បន្ទាប់មក លោកនាយកក្រុមហ៊ុន បានជម្រាបជូនលោក-លោកស្រីជាសមាជិកអង្គប្រជុំអំពីមូលហេតុដែលក្រុមហ៊ុនសម្រេចស្នើសុំព្យួរកិច្ចសន្យាការងារបងប្អូនកម្មករនិយោជិត យ៉ាងដូច្នេះថាៈ មួយរយៈចុងក្រោយនេះ ក្រុមហ៊ុនបានជួបប្រទះនូវការខ្វះខាតសម្ភារៈ (វត្ថុធាតុដើម) សម្រាប់ដំណើរការផលិតកម្ម និងដោយសារ ការបញ្ជាទិញក៏មានការធ្លាក់ចុះ ទើបក្រុមហ៊ុនសម្រេចស្នើរសុំព្យួរកិច្ចសន្យាការងារបងប្អូនកម្មករនិយោជិត មួយរយៈពេល។

ភាគីតំណាងកម្មករនិយោជិត (ប្រតិភូបុគ្គលិក) ឯកភាពទាំងស្រុងចំពោះការលើកឡើងរបស់លោកនាយកក្រុមហ៊ុន ក្នុងនោះតាមការសង្កេតជាក់ស្តែង គឺក្រុមហ៊ុនមិនមានការងារគ្រប់គ្រាន់ជូនបងប្អូនកម្មករពិតប្រាកដមែន។

ក្រោយពីបានពិភាក្សា និងសហការណ៍គ្នាយ៉ាងមុតមាំរួចមក អង្គប្រជុំសម្រេចបានលទ្ធផលដូចខាងក្រោមៈ

១-ក្រុមហ៊ុនសម្រេចព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ៧៣៨នាក់ ក្នុងចំនួនកម្មករនិយោជិតសរុប ៧៣៨ នាក់ រយៈពេល ០១ខែ គិតចាប់ពីថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០២០ ដល់ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ២០២០។

២-ភាគីក្រុមហ៊ុនឯកភាពផ្តល់ប្រាក់ឧបត្ថម្ភចំនួន ៣០ ដុល្លាអាមេរិក ( សាមសិបដុល្លាអាមេរិក ) ក្នុងរយៈពេល ២១ ថ្ងៃដល់ ០១ ខែ ហើយក្រុមហ៊ុននឹងបើកផ្តល់ជូនបងប្អូនកម្មករនិយោជិត ១ដងក្នុងមួយខែ គឺថ្ងៃទី ១០ នៃខែបន្ទាប់។ បងប្អូនកម្មករត្រូវត្រលប់ចូលធ្វើការជាធម្មតាតាមក្រុម ឬវេនរៀងៗខ្លួនវិញនៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០២០។

៣-ប្រសិនបើក្រុមហ៊ុនទទួលបានសម្ភារៈ (វត្ថុធាតុដើម) និងការបញ្ជាទិញពីម្ចាស់ទំនិញឡើងវិញ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុននឹងជូនដំណឹងឱ្យបងប្អូនកម្មករត្រលប់ចូលធ្វើការងារវិញតាមក្រុម/វេនរៀងៗខ្លួន។

កំណត់ហេតុបានចប់សព្វគ្រប់នៅវេលាម៉ោង ១១:០០ នាទីព្រឹក នាថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសយោគយល់ អធ្យាស្រ័យ និងស្និទ្ធស្នាលក្រៃលែង ។

| នាយកក្រុមហ៊ុន | តំណាងកម្មករ | | | លេខាកត់ត្រា |
|---|---|---|---|---|
| | ពុត សាមឿន | សយ សំណាង | កង សុវណ្ណារី | |
| | កែវ ច័ន្ទធុល | រឿន ផល្លី | ហេង សុភាព | |
| QUE WENLOU | ជា ពៅ | ជុំ កាន់ | | សម ចរិយា |

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន លៀនហ្វា (ខេមបូឌា) ហ្គាមេន LIANFA (CAMBODIA) GARMENT CO.,LTD. KINGDOM OF CAMBODIA